Denti-Cal

កម្មវិធីមាត់ធ្មេញ Medi-Cal ប្រចាំរដ្ឋ California

សមាជិក Medi-Cal ជាទីរាប់អាន៖

តើលោកអ្នកបានដឹងទេថា លោកអ្នកអាចមានអត្ថប្រយោជន៍ផ្នែកធ្មេញដែលបានធានារ៉ាប់រងដោយ Medi-Cal ឬទេ? កំណត់ត្រារបស់យើងបង្ហាញថា លោកអ្នក ឬកូនរបស់លោកអ្នកមិនបានប្រើ អត្ថប្រយោជន៍ផ្នែកធ្មេញ Medi-Cal (Denti-Cal) ក្នុងរយៈពេល 12 ខែកន្លងមកហើយ។

សុខភាពមាត់ធ្មេញគឺជាផ្នែកសំខាន់មួយនៃសុខភាពសម្រាប់រាងកាយទាំងមូលរបស់លោកអ្នក! អ្នករាល់គ្នាគួរតែឱ្យគេពិនិត្យធ្មេញយ៉ាងហោចណាស់ម្តងជារៀងរាល់ឆ្នាំ។ ទន្តពេទ្យអាចណែនាំពេលវេលាខុសគ្នាសម្រាប់លោកអ្នក ឬកូនរបស់លោកអ្នក។

- **វាមិនដែលលឿនពេកនោះទេសម្រាប់ការថែទាំធ្មេញ។** ធ្មេញព្រៃរបស់កូនលោកអ្នកអាចប៉ះពាល់ដល់សុខភាពនៃធ្មេញពេញវ័យ។
- **បញ្ឈប់ដង្កូវស៊ីធ្មេញ។** ជួបទន្តពេទ្យដើម្បីទទួលការពិនិត្យ ការសម្អាត និងសេវាទន្តសាស្ត្រដែលអាចបង្ការការពុកធ្មេញ។
- **ធានាថារាងកាយមានសុខភាពល្អ។** ការមានអញ្ចាញធ្មេញមានសុខភាពល្អអាចបន្ថយការផ្លាស់ប្តូរនៃការអភិវឌ្ឍបញ្ហាវេជ្ជសាស្ត្រផ្សេងៗបាន។

សូមទូរស័ព្ទមកសេវាអតិថិជន Denti-Cal តាមលេខ **1-800-322-6384**។ យើងបើកពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ម៉ោង 8:00 ព្រឹក ដល់ម៉ោង 5:00 ល្ងាច។ យើងអាចជួយលោកអ្នកជាមួយ៖

- ការស្វែងរកទន្តពេទ្យ។
- ការរៀបចំពេលវេលាណាត់ជួបទន្តពេទ្យ។
- ការស្វែងយល់បន្ថែមអំពីអត្ថប្រយោជន៍ផ្នែកធ្មេញរបស់លោកអ្នក។
- ការឆ្លើយនូវសំណួរអំពីកម្មវិធី Denti-Cal។
- ការទទួលព័ត៌មានស្តីពីការក្លែងបន្លំ និងការរំលោភបំពាន។
- ការទទួលព័ត៌មានស្តីពីការដោះស្រាយបញ្ហាជាមួយនឹងការថែទាំធ្មេញ។

ត្រូវប្រាកដថានិយាយអំពីលិខិតនេះនៅពេលលោកអ្នកទូរស័ព្ទមក។

លោកអ្នកក៏អាចចូលមើល www.denti-cal.ca.gov សម្រាប់ព័ត៌មានអំពី Denti-Cal។

ដោយក្តីរាប់អានដ៏ស្មោះស្ម័គ្រ

កម្មវិធីធ្មេញ Medi-Cal របស់ក្រសួងសេវាកម្មថែទាំសុខភាព